- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ស ម្រេ ច

ប្រការ ១.-

ត្រូវបានកំណត់យកថ្ងៃទី ២១ ខែ មិថុនា រៀងរាល់ឆ្នាំ ជាទិវាអតីតយុទ្ធជនកម្ពុជា ។

ប្រការ ២.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ចណែនាំ អនុវត្តទិវាអតីតយុទ្ធជនកម្ពុជា ឱ្យបានល្អ ។

ប្រការ ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអាជ្ញាធរខេត្ត ក្រុង ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ: ៤៥៧ សហវ.ប្រក.ចមក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០៧

ប្រកាសអន្តរក្រសួង

ស្តីពី

កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និង កម្រៃរដ្ឋបាលពាក់ព័ន្ធនានា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១៩៦/១៦/៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការ

គ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ

- បានឃើញ ព្រះរាជក្រមលេខ នស/រកប/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ប.ក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក. ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យ លេខ ៦៤ អនក្រ បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពី ការអនុវត្តច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំ លេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពី រដ្ឋទេយ្យចំណូល
- អនុវត្តតាមសារាចរណែនាំ លេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា
- អនុវត្តន៍តាមបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យយកកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ដូចជាការបញ្ជាក់ អំពីការប្រើប្រាស់ ឬ មិនប្រើប្រាស់ម៉ាក ការផ្លាស់ប្តូរផ្សេងៗ ការលុបម៉ាកចេញពីបញ្ជី ការចុះបញ្ជីសាឡើងវិញ និង ការបោះពុម្ពផ្សាយ ។

ប្រការ ២ : ត្រូវបានកំណត់កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ពន្ធ័នានា ដូចខាងក្រោម :

ល.រ	ពិពណ៌នា	ឯកត្តា	តម្លៃ (គិតជាប្រាក់រៀល)
	I- ការចុះបញ្ជីម៉ាក		
១-	ការដាក់ពាក្យសុំចុះបញ្ជីម៉ាក	មួយម៉ាក និងមួយជំពូក	២០.០០០ រៀល
២-	ការចុះបញ្ជីម៉ាក (សុពលភាព ១០ឆ្នាំ)	មួយម៉ាក និងមួយជំពូក	១៨០.០០០ រៀល
	II- ការបញ្ជាក់ អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក		
៣-	ការដាក់ពាក្យ និង ការបញ្ជាក់ អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក	មួយម៉ាក និងមួយជំពូក	៤០.០០០ រៀល
	III- ការផ្លាស់ប្តូរផ្សេងៗ		
៤-	ការកត់ត្រា ការផ្ទេរកម្មសិទ្ធិម៉ាក (Assignment)	មួយម៉ាក និងមួយជំពូក	៤០.០០០ រៀល
៥-	ការកត់ត្រា ការប្តូរឈ្មោះ ឬការរួមបញ្ចូលគ្នា នៃម្ចាស់ម៉ាក (Name Change and Merger)	មួយម៉ាក និងមួយជំពូក	៤០.០០០ រៀល
៦-	ការកែតម្រូវនានា (ជាកំហុសរបស់អ្នកដាក់ពាក្យ)	មួយម៉ាក និងមួយជំពូក	៤០.០០០ រៀល
៧-	ការកត់ត្រា ការប្តូរឈ្មោះអាសយដ្ឋាន (Address Change) (ក្នុងករណីប្តូរតែអាសយដ្ឋានមួយប៉ុណ្ណោះ)	មួយម៉ាក និងមួយជំពូក	៤០.០០០ រៀល
	IV- ការលុបម៉ាក		
៨-	ការលុបម៉ាកចេញពីបញ្ជី (បង់ដោយអ្នកស្នើសុំលុប)	មួយវិញ្ញាបនប័ត្រ	២០០.០០០ រៀល

	V- **ការចុះបញ្ជីម៉ាកសាឡើងវិញ**		
៩-	ការដាក់ពាក្យ និងការចុះបញ្ជីម៉ាកសាឡើងវិញ	មួយម៉ាក និងមួយជំពូក	២០០.០០០ រៀល
	VI- **ការបោះពុម្ពផ្សេងទៀត (ប្រសិនជាមាន)**		
១០-	ទំហំតូចជាង ១/៣ នៃក្រដាស A4	មួយឯកត្តា	៤០.០០០ រៀល
១១-	ទំហំ ១/៣ នៃក្រដាស A4	មួយឯកត្តា	៨០.០០០ រៀល
១២-	ទំហំ ១/២ នៃក្រដាស A4	មួយឯកត្តា	១២០.០០០ រៀល
១៣-	ទំហំ ៣/៤ នៃក្រដាស A4	មួយឯកត្តា	២០០.០០០ រៀល
១៤-	ទំហំ A4	មួយឯកត្តា	៤០០.០០០ រៀល

ប្រការ ៣ : ក- ការគ្រប់គ្រងចំណូលពីកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ត្រូវអនុវត្តតាមនីតិវិធី នៃកិច្ចសហប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៨ ដោយត្រូវបង់ ១០០% ចូលថវិការដ្ឋ ។

ខ- ចំពោះចំណូល ដែលប្រមូលបានដោយក្រសួងពាណិជ្ជកម្ម ត្រូវបង់ចំណូលនេះចូលរតនាគារជាតិ ដោយអនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

គ- ក្រសួងពាណិជ្ជកម្ម ត្រូវបូកសរុបធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

ប្រការ ៤ : ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ត្រូវអនុវត្ត តាមរយៈរដ្ឋលេខាធិការទទួលបន្ទុកចំណូលនៅក្រសួងពាណិជ្ជកម្ម។

ប្រការ ៥ : ការផ្តល់ប្រាក់ឧបត្ថម្ភដល់ការងារគ្រប់គ្រង និង ប្រមូលចំណូលនេះ នឹងត្រូវរៀបចំប្រកាសអន្តរក្រសួងមួយដោយឡែក តាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ។

ប្រការ ៦ : កម្រៃរដ្ឋបាលក្នុងការបោះពុម្ពផ្សាយម៉ាក ដែលបានចុះបញ្ជីរួចហើយ ក្នុងព្រឹត្តិប័ត្រផ្លូវការ នឹងត្រូវកំណត់នៅពេលក្រោយ ។

៩៦

ប្រការ ៧ : បទប្បញ្ញត្តិ ឬ ប្រកាសទាំងឡាយ ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៨ : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

<u>ចម្លងជូន៖</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-គ្រប់ខេត្ត-ក្រុង
-ដូចប្រការ ៨ ដើម្បីអនុវត្ត
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៧០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៧

ប្រកាស
ស្តីពី
អត្រាបុព្វលាភនៃការធានារ៉ាប់រងអគ្គីភ័យ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង

- បានឃើញលក្ខន្តិកៈ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៥ របស់សមាគមធានារ៉ាប់រងទូទៅកម្ពុជា

សម្រេច

ប្រការ ១ : បទប្បញ្ញត្តិទូទៅ

ដោយអនុលោមតាមមាត្រាទី ៨៩ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានឯកភាពជាមួយសមាគមធានារ៉ាប់រងទូទៅកម្ពុជា «សធទក» លើអត្រាបុព្វលាភអប្បបរិមានៃការធានារ៉ាប់រងអគ្គីភ័យ ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ។ រាល់ការផ្លាស់ប្តូរទាំងឡាយ ដែលនាំឱ្យមានការកែប្រែតារាងអត្រាបុព្វលាភនេះ ត្រូវមានការយល់ព្រមជាមុន ជាលាយលក្ខអក្សរ ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

គ្រប់សមាជិកទាំងអស់របស់សមាគមធានារ៉ាប់រងទូទៅកម្ពុជា ត្រូវអនុវត្តតាមតារាងអត្រាបុព្វលាភធានារ៉ាប់រងនេះ ដោយអនុលោមទៅតាមមាត្រា ៨ក នៃលក្ខន្តិកៈរបស់សមាគមធានារ៉ាប់រងទូទៅ នេះ ។ សមាគមធានារ៉ាប់រងទូទៅកម្ពុជា មានភារៈទទួលខុសត្រូវ និង ពង្រឹងការអនុវត្ត នូវអត្រាបុព្វលាភធានារ៉ាប់រងអគ្គីភ័យនេះ ។

ប្រការ ២ : ការរំលោភទៅលើអត្រាបុព្វលាភ

ក្នុងករណីដែលសមាគមពិនិត្យឃើញថា មានការរំលោភលើអត្រាបុព្វលាភ ដែលបានអនុម័តរួចនេះ ពិតប្រាកដមែន ក្រុមប្រឹក្សាវិន័យរបស់សមាគម នឹងពិចារណាក្នុងការដាក់ពិន័យទៅលើសមាជិកណា ដែលបានរំលោភ តាមកំរិតដូចខាងក្រោមនេះ :

ក- ចំពោះការរំលោភលើកទី ១ សមាជិកដែលបានប្រព្រឹត្តនូវការរំលោភនេះ នឹងត្រូវបានកោះហៅ ឱ្យមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាវិន័យ ដើម្បីធ្វើការពន្យល់ និង ធ្វើការកែតម្រូវជាបន្ទាន់មួយ សម្រាប់ភាពដែលមិនប្រក្រតី ។

ខ- ការផាកពិន័យជាទឹកប្រាក់ក្នុងចន្លោះ ពី ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅ ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក នឹងអនុវត្តលើសមាជិកណា ដែលបានរំលោភលើអត្រាបុព្វលាភនេះ ជាលើកទី ២ ។

គ- ក្នុងករណីមានការរំលោភជាលើកទី ៣ ដោយមិនរាងចាល សមាជិកនោះ នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ក្នុងចន្លោះពី ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ទៅ ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក ។

ឃ- ក្រុមប្រឹក្សាវិន័យនឹងបង្វែរការដាក់ទណ្ឌកម្មពិន័យនេះ ទៅឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងករណីដែលមិនរាងចាល ដោយប្រព្រឹត្តរំលោភលើបញ្ញត្តិនៃប្រកាសនេះ ចាប់ពីលើកទី ៤ ឡើងទៅ ។

ប្រាក់ពិន័យដែលទទួលបានសំរាប់ចំនុច «ខ» និង «គ» ត្រូវបង់ដោយផ្ទាល់ទៅសមាគមធានារ៉ាប់រងទូទៅកម្ពុជា ។

ប្រការ ៣ : នីតិវិធីដាក់ពិន័យ

រាល់ការរំលោភទាំងឡាយ ទៅលើតារាងអត្រាបុព្វលាភ នឹងត្រូវដោះស្រាយដោយសមាគមធានារ៉ាប់រងទូទៅកម្ពុជា ដោយផ្អែកទៅលើមាត្រា ១៨ នៃលក្ខន្តិកៈរបស់សមាគម ។

ក្រុមប្រឹក្សាវិន័យដែលនឹងត្រូវស៊ើបអង្កេតអំពីការរំលោភទៅលើតារាងអត្រាបុព្វលាភនេះ ត្រូវមាន សមាជិកយ៉ាងតិច ៣ រូប ដែល ១ រូប ក្នុងចំណោមនោះ គឺជាតំណាងមកពីវិទ្យាស្ថានកម្ពុជា សំរាប់គណនេយ្យករសាធារណៈ និងសវនករ ។ ប្រធានក្រុមប្រឹក្សាវិន័យ គឺជាប្រធានសមាគមធានារ៉ាប់រងទូទៅកម្ពុជា ឬតំណាងដែលទទួលការតែងតាំងពីប្រធានសមាគមនេះ ។

ប្រការ ៤ : ការចូលជាធរមាន

ប្រកាសនេះនឹងចូលជាធរមាន បន្ទាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ ប្រធានសមាគមធានារ៉ាប់រងទូទៅកម្ពុជា ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលជាសមាជិកសមាគម ត្រូវអនុវត្ត និង ប្រតិបត្តិតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

នេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និងអធិការកិច្ច
Ministry of National Assembly-Senate Relations and Inspection

លេខ : ០៨១/០៧ ទ.រ.ព.អ.(ស.ក)

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៧

ប្រកាស
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅ
របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង
នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស / ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៩ / ០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៣០០ / ១០ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០២ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ./.

- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បកចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ២៣៣ អនក្រ.តត ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៧ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ
- យោងតាមការចាំបាច់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ស ម្រេ ច

ប្រការ ១ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យ ស្របតាមស្តង់ដារ និងក្រមសីលធម៌វិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង ដើម្បីវិភាគវាយតម្លៃលើសកម្មភាពក្នុងគោលដៅ បង្កើនប្រសិទ្ធិភាពការងារនៅតាមអង្គភាពថ្នាក់កណ្តាល និងមន្ទីរតាមបណ្តាខេត្ត-ក្រុងក្រោមឱវាទក្រសួង ។ ដើម្បីសំរេចគោលដៅនេះ សវនករត្រូវមានសិទ្ធិ សេរីភាពពេញលេញក្នុងការត្រួតពិនិត្យលើគ្រប់សកម្មភាព គ្រប់ផ្នែករាល់បញ្ជីការកត់ត្រាទ្រព្យសម្បត្តិរដ្ឋ និងបុគ្គលិក ។

ប្រការ ២ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាអង្គភាពមួយចំណុះឱ្យក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានភារកិច្ចដូចខាងក្រោម :

១. រៀបចំផែនការសវនកម្មប្រចាំឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច ។

២. ពិនិត្យឡើងវិញលើមុខងារ សកម្មភាព កិច្ចសហប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តន៍ឱ្យបានត្រឹមត្រូវ លើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីនៃ ការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព ។

៣. កំណត់នូវភាពសមស្របគ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព ។

៤. ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់ នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណវាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ ។

៥. ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាថាតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ បទបញ្ញាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍ ។ ក្នុងករណីអង្គភាពអនុវត្តពុំបានសម្រេចដូចបានរៀបរាប់ខាងលើ ចាំបាច់សំណូមពរឱ្យមានការផ្លាស់ប្តូរ និងកែលំអ ។

៦. ពិនិត្យឡើងវិញការគ្រប់គ្រង ថែទាំ ការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមាន ឱ្យបានត្រឹមត្រូវ ។

៧. វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធិភាពលើការប្រើប្រាស់ធនធាន និងកំណត់ការកែលំអលើការអនុវត្តន៍កិច្ចប្រតិបត្តិការ និងផ្តល់អនុសាសន៍ ។

៨. ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធី និងគំរោងចំណាយមូលធន លើលទ្ធផលការងារវិជ្ជមាន ឬអវិជ្ជមាន តាមគោលបំណង គោលដៅដែលបានដាក់ចេញ និងតាមផែនការដែលបានកំណត់ ។

៩. ចូលរួមបង្កើតផែនការ ការអភិវឌ្ឍន៍ ការអនុវត្តន៍ និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗដើម្បីធានាឱ្យ :

ក- តម្រូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាស់លាស់ ។

ខ- ការត្រួតពិនិត្យផ្ទៃក្នុងសមស្របត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ។

គ- ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រត្រូវបានប្រព្រឹត្តទៅក្នុងជំហានសមស្រប ។

ឃ- ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ ។

១០. ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរ ការទិន្នន័យសំខាន់ៗ ក្រោយពេលតឡើងរួច ដើម្បីកំណត់ប្រព័ន្ធនេះ ឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផលមានសុវត្ថិភាព និងប្រសិទ្ធិភាពខ្ពស់ ។

១១. ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តន៍ដើម្បីធានាថា វិធានការត្រូវបានដាក់ចេញក្នុងគោលបំណងការពារ ការកេងបន្លំ ។ ប្រសិនបើមានការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញទាន់ពេលវេលា ។

១២. ពិនិត្យឡើងវិញលើការអនុវត្តន៍ តាមគោលការណ៍ណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ស្តីពីឥរិយាបថ និងក្រមសីលធម៌ចំពោះមន្ត្រីរាជការ ។

១៣. សំរបសំរួលការងារសវនកម្មផ្ទៃក្នុង ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា ។

១៤. ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ហើយត្រូវធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះ ទៅអាជ្ញាធរសវនកម្មជាតិស្តីពី :

ក- សកម្មភាពកែលំអតាមអនុសាសន៍សំខាន់ៗរបស់សវនកម្មផ្ទៃក្នុង ។

ខ- សកម្មភាពសវនកម្មត្រូវបានផ្តោតលើហានិភ័យ និងបង្កើតភាពសន្សំសំចៃប្រសិទ្ធិភាព និងការផ្តល់លទ្ធផលល្អក្នុងកិច្ចសហប្រតិបត្តិការ ។

គ- សវនកម្មផ្ទៃក្នុងត្រូវធ្វើការសម្របសម្រួលការងារជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីជៀសវាងការធ្វើសវនកម្មស្ទួនគ្នា ។ ក្នុងករណីមានភាពមិនច្បាស់លាស់ អាជ្ញាធរសវនកម្មជាតិអាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មសារឡើងវិញ ។

ឃ- ផែនការសវនកម្មផ្ទៃក្នុង ត្រូវមានភាពសមស្របច្បាស់លាស់ គ្រប់គ្រាន់ ។

ង- ការរារាំងលើព័ត៌មាន និងបញ្ជី ។

១៥. វាយតម្លៃផែនការ ឬសកម្មភាពកែលំអលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង ។ ប្រសិនបើសកម្មភាពកែលំអនេះមិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្តដើម្បីសំរេចតាមសំណូមពរដែលអាចទទួលយកបាន ។

១៦. ផ្តល់លទ្ធភាពសមស្របគ្រប់គ្រាន់ក្នុងការតាមដានសកម្មភាពកែលំអលើអនុសាសន៍ ។

១៧. ប្រធានសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនថ្នាក់ដឹកនាំក្រសួង ។

១៨. ធ្វើរបាយការណ៍ និងសន្និដ្ឋាននៃសវនកម្ម ផ្ញើជូនដល់អង្គភាពនីមួយៗក្រោមឱវាទក្រសួងដែលទទួលបន្ទុកកែលំអតាមអនុសាសន៍ ។ សវនកម្មផ្ទៃក្នុងត្រូវបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន ។

១៩. អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗ ដែលក្រសួងប្រគល់ជូន ។

ប្រការ ៣ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដឹកនាំដោយប្រធាន ១រូប និងអនុប្រធានមួយចំនួន ជាជំនួយការទៅតាមការចាំបាច់ ។

ប្រការ ៤ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានការិយាល័យចំណុះចំនួន ៣ ដូចខាងក្រោម :

១- ការិយាល័យរដ្ឋបាល សវនកម្ម

២- ការិយាល័យសវនកម្មទី១

៣- ការិយាល័យសវនកម្មទី២

ប្រការ ៥ :

តួនាទី និងភារកិច្ចរបស់ការិយាល័យរដ្ឋបាល និងការទទួលបន្ទុកធ្វើសវនកម្មរបស់ការិយាល័យសវនកម្មនីមួយៗលើអង្គភាពក្រោមឱវាទក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត-ក្រុង មានដូចខាងក្រោម :

១- ការិយាល័យរដ្ឋបាលសវនកម្ម មានភារកិច្ច :

- គ្រប់គ្រង ចរាចរឯកសាររដ្ឋបាល ឯកសារគតិយុត្ត ឯកសារបច្ចេកទេស និងឯកសារឡេីនស្ទូត្រ
- កសាងផែនការរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង របស់នាយកដ្ឋាន
- រៀបចំកម្មវិធី និងកាលវិភាគការងារជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងទទួលបន្ទុកការងារពិធីការ
- បូកសរុប និងធ្វើរបាយការណ៍នានា និងសរុបផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ចូលរួមសហការលើការធ្វើសវនកម្ម តាមបណ្តាអង្គភាពនានា
- ធានាប្រក្រតីភាពកិច្ចការរដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់ និងពង្រឹងការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងរបស់នាយកដ្ឋាន
- លើកគំរោងស្តីពីតម្រូវការចលនទ្រព្យ និងអចលនទ្រព្យប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងបញ្ជីចលនវត្ថុ និងអចលនវត្ថុ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់នាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ

២- ការិយាល័យសវនកម្មទី១ ទទួលបន្ទុកធ្វើសវនកម្ម :

- នាយកដ្ឋាននិងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត-ក្រុង និងអង្គភាពចំណុះ
  - នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
  - នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
  - នាយកដ្ឋានទំនាក់ទំនងជាមួយអធិការកិច្ចតាមបណ្តាស្ថាប័ន
  - នាយកដ្ឋានអធិការកិច្ច
  - នាយកដ្ឋានតាមដានការអនុវត្តន៍ច្បាប់
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រាជធានីភ្នំពេញ
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកណ្តាល
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តតាកែវ
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពត
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រុងកែប
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តស្វាយរៀង
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តព្រៃវែង
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពង់ចាម
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តក្រចេះ
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តស្ទឹងត្រែង
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តរតនគិរី
  - មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តមណ្ឌលគិរី

៣- ការិយាល័យសវនកម្មទី២ ទទួលបន្ទុកធ្វើសវនកម្ម :

- នាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ
- នាយកដ្ឋានវិវាទកម្ម
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា
- នាយកដ្ឋានអប់រំ ផ្សព្វផ្សាយច្បាប់
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តព្រះវិហារ
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពង់ធំ
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពង់ស្ពឺ
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រុងព្រះសីហនុ
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រុងប៉ៃលិន
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តបាត់ដំបង
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តបន្ទាយមានជ័យ
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តឧត្តរមានជ័យ
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តសៀមរាប
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពង់ឆ្នាំង
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកោះកុង
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តពោធិ៍សាត់
- **ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ**

ប្រការ ៦ :

ការិយាល័យសវនកម្មនីមួយៗមានភារកិច្ចដូចខាងក្រោមនេះ :

- សហការរៀបចំផែនការសវនកម្មប្រចាំឆ្នាំជូនថ្នាក់ដឹកនាំនាយកដ្ឋានពិនិត្យ និងសម្រេច
- ធ្វើសវនកម្មលើមុខងារ រចនាសម្ព័ន្ធ ទស្សនទាន យុទ្ធសាស្ត្រ កម្មវិធី វិធានការ បទបញ្ជា មធ្យោបាយ និងការចាត់តាំងការងាររបស់អង្គភាព ឱ្យស្របតាមនីតិវិធីបច្ចុប្បន្នភាពនៃសមោកាសគោលការណ៍ណែនាំថ្នាក់ដឹកនាំ និងកម្មវត្ថុរបស់អង្គភាព
- ធ្វើសវនកម្មលើការអនុវត្តច្បាប់ បទបញ្ជានានា វិន័យថវិកាគណនេយ្យ-ហិរញ្ញវត្ថុ និងអភិបាល-កិច្ចល្អ នៅក្នុងការប្រតិបត្តិការហិរញ្ញវត្ថុ ពិសេសការគៀងគរ និងគ្រប់គ្រងចំណូល ចំណាយថវិកាហិរញ្ញប្បទាន បំណុល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ធ្វើសវនកម្មរាល់ពាក្យបណ្តឹងរបស់បណ្តាអង្គភាពក្រោមឱវាទក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

- រក្សារបាយការណ៍សវនកម្មឱ្យបានល្អ សំរាប់ជាមូលដ្ឋានតាមដានផ្ទៀងផ្ទាត់លើវឌ្ឍនភាព នៃការអនុវត្តអនុសាសន៍កែលំអ
- ផ្តល់សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ព្រមទាំងរបាយការណ៍ជូនប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
- តាមដានជាប្រចាំនូវឯកសារគតិយុត្តិ និងសកម្មភាពកែទំរង់គណនេយ្យ និងហិរញ្ញវត្ថុសាធារណៈរបស់អង្គភាពនីមួយៗ
- ចូលរួមសហការជាមួយអង្គភាព និងស្ថាប័នដែលពាក់ព័ន្ធ សំដៅកសាងមូលដ្ឋានព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ និងមានភាពសុក្រឹត
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រការ ៧ :

អគ្គនាយក ប្រធានគ្រប់អង្គភាពចំណុះក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ម៉ែន_សំអន

<u>**កន្លែងទទួល**</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ខុទ្ទកាល័យ ជិទាវទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ដូចមានចែងក្នុងប្រការ ៧

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៨ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០៧

[illegible]
ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០០៧

សារាចរណែនាំ

ស្តីពីការបន្ថែមប្រាក់ពី១៥ទៅ២៥ភាគរយជូន ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន

យោងអនុក្រឹត្យលេខ ៤៥ អនក្រ បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបន្ថែមបៀវត្ស ជូនកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ ។

យោងសារាចរណែនាំលេខ ០៣ សអយ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតំឡើងប្រាក់របប ១៥ ភាគរយ ជូនជនពិការ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន ។

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើការណែនាំអនុវត្ត ដូចខាងក្រោម :

១-របៀបបន្ថែមប្រាក់ពី ១៥ ទៅ ២៥ ភាគរយ ត្រូវអនុវត្តតាមរូបមន្តដូចតទៅ :

-ក-ចំពោះជនពិការគ្រប់ប្រភេទ និវត្តជន និងជនបាត់បាត់បង់សមត្ថភាពការងារ ជាអតីតកងកម្លាំងប្រដាប់អាវុធ ម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្ត : $\frac{\text{១០ x បៀវត្សរ៍ឋានន្តរសក្តិ}}{\text{១០០}}$

-ខ-ចំពោះជនពិការ ជាអតីតក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្ត : $\frac{\text{១០ x បៀវត្សរ៍សុទ្ធសាធ}}{\text{១០០}}$

-គ-ចំពោះជនពិការ ជាអតីតកងសេនាជន ប្រជាជន កងជីវពល ម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្ត : $\frac{\text{១០ x បៀវត្សរ៍ឋានន្តរសក្តិពលទោ}}{\text{១០០}}$

២-ប្រាក់បន្ថែមដូចបានកំណត់ក្នុងចំណុចទី១ ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៧ នេះតទៅ និងត្រូវបញ្ចូលក្នុងបញ្ជីរាយនាមជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ទៅក្នុងខ្ទង់ប្រាក់បន្ថែមភាគរយ ។

៣-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់ខេត្ត ក្រុង ត្រូវបំពេញបែបបទ និងស្នើសុំសេចក្តីសម្រេច ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្ត ។

- នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវពិនិត្យ និង លើកមតិជូនឯកឧត្តមរដ្ឋមន្ត្រីសម្រេចជាផ្លូវការ ។

នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋាន នាយកដ្ឋានសោធនអតីតយុទ្ធជន នាយកដ្ឋានពាក់ព័ន្ធ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត.ក្រុង ត្រូវអនុវត្តសារាចរណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឥទ្ធិ សំហេង

ចម្លងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្តក្រុង
- គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៩៩៣៤ **ពណ.នគក**

ភ្នំពេញថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហាណារ៉ូ ផ្លាស**
HANARO PLUS Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3406/07E ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក NOH SUNGGIL

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៧៦ ផ្លូវលេខ ២៤៥ ក្បាលដី ៦ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការផ្គត់ផ្គង់សំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន - វិទ្យាស្ថានអប់រំ - មជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ញឹម ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវ៉ាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៥៤១ ពណ.នគក

ភ្នំពេញថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អាយរ៉ុន អេន ស្ទីល ម៉ាញនីង ត្រេឌីង គ្រុប**
IRON AND STEEL MINING TRADING GROUP Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3392/07E ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក ZHANG CHUAN YOU ប្រធានក្រុមប្រឹក្សាភិបាល
លោក WU GUO SHENG អភិបាល
លោក LI GUANG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៥០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៨ ផ្លូវលេខ ២៨១ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើនៅក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
- សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ -សិក្សាគំរោងប្លង់ និងគ្រឿងគ្រប់ប្រភេទ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៥៩៤ ពណ.នតក

ភ្នំពេញថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ីឃ្យួរីធី សឺវីស អាស៊ី ខូអិលធីឌី**
SECURITY SERVICES ASIA CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9581/07P ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
- លោកស្រី **សុខ សុភាំត្រា** ប្រធានក្រុមប្រឹក្សាភិបាល
- លោក JOHN EDWARD MULLER អភិបាល
- លោក CHRISTIAN LEONARD BERGER អភិបាល
- លោក DIMITAR VASKOV IVANOV អភិបាល
- លោកស្រី **ឌាន ចូរ៉ែន្ទុន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១១ B ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -បំរើសេវាកម្មសន្តិសុខឯកជន ការពារ-ការដឹកជញ្ជូនប្រាក់ ស្រាវជ្រាវស៊ីវិល ការពារសន្តិសុខដោយប្រព័ន្ធអេឡិចត្រូនិច ស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងរបស់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងការពារសុវត្ថិភាពជូនដល់ វិនិយោគិន ពាណិជ្ជករ អាជីវករ រោងចក្រ សហគ្រាស ឃ្លាំងសំភារៈ លំនៅដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន ក្រុមហ៊ុនឯកជន ធនាគារ សាលារៀន រមណីយដ្ឋាន ផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម និងអង្គការនានា
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-សេវាដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញគ្រប់ប្រភេទ
-សេវាជួសជុល សាងសង់អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត ភ្នាក់ង[illegible]

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.រដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ-ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍-ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៥៩០ ពណ.នគក

ភ្នំពេញថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **យុគវឌ្ឍនៈផុង ឧត្តរមានជ័យ** YUKWATTANAPONG OUDOR MEANCHEY Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 3407/07E ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា	: សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោក KAMOL YUKWATTANAPONG
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ភូមិស្រែល្ហួយ ឃុំស្រែល្ហួយ ស្រុកវ៉ារិន ខេត្តសៀមរាប ។
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការផ្គត់ផ្គង់សំភារៈ ទំនិញគ្រប់ប្រភេទ -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ -សេវាយកកំរៃជើងសារលើការដឹកជញ្ជូន -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ ✓
- សាលាខេត្តសៀមរាប
- មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៨៦១ **ពណ.នតក**

ភ្នំពេញថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **ឡាយ ហ្គ្រីន វេ**
	LAY GREEN WAY Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: **Co. 9576/07P** ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោកស្រី **នខ ស៊ីថាត** ប្រធានក្រុមប្រឹក្សាភិបាល
